**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**
សំណុំរឿងរដ្ឋប្បវេណីលេខ ១០៣
ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១
**សាលក្រមលេខ: ០២៩ (ធ)**
ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣

*តាងនាមប្រជារាស្ត្រខ្មែរ*
**សាលាដំបូងខេត្តកណ្តាល**
បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់
នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣

*ដោយមានសមាសភាព:*

លោក [redacted] ចៅក្រម
លោក [redacted] ក្រឡាបញ្ជី

-ដើមចោទឈ្មោះ[redacted]យ៉ា ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរ នគរបាល ទីលំនៅបច្ចុប្បន្ន [redacted]។

អ្នកតំណាងដោយអាណត្តិ ឈ្មោះ[redacted]អត្តលេខ ២២៦ ,ឈ្មោះ[redacted]អត្តលេខ ២៧៣០ T និងឈ្មោះ[redacted]អត្តលេខ ២៧៤៨T។

-ចុងចម្លើយឈ្មោះ [redacted] លីវ៉ាន់នី ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ មេផ្ទះ ទីលំនៅ [redacted]។

## អង្គហេតុ និងចំណុចវិវាទ

*១-ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:*

១-ប្តឹងសុំលែងលះប្រពន្ធឈ្មោះ [redacted]លីវ៉ាន់នី (ចុងចម្លើយ)។

២-សិទ្ធិគ្រប់គ្រងកូនឈ្មោះ[redacted]សុវណ្ណឧត្តម ភេទប្រុស កើតថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥ ។

៣-បែងចែកទ្រព្យសម្បត្តិរួម។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

*២-ការពន្យល់ត្រួសៗអំពីរឿងក្តី:*

ដើមចោទឈ្មោះ [redacted] រ៉ាយ៉ា និងចុងចម្លើយឈ្មោះ[redacted] លីវ៉ាន់នី បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខៈ០៨ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤។ ក្នុងការរស់នៅជាមួយគ្នា ដើមចោទ និងចុងចម្លើយមានកូនចំនួន ០១នាក់ គឺឈ្មោះ [redacted]សុវណ្ណឧត្តម ភេទប្រុស កើតថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ នឹងមានទ្រព្យសម្បត្តិរួមមួយចំនួនដូចជា៖ ដីឡូតិ៍ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៤០៧០៨០៦.១៤៩៩លេខក្បាលដី១៤៩៩ ទំហំ២២៦ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែសារ ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង,ផ្ទះល្វែងស្ថិតនៅបុរី ប៊ីអូអេស (BOS)ក្បាលដីលេខ ២៣៦ ផ្ទះលេខ B14 ភូមិព្រៃសណ្តែក សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ,ម៉ូតូ០១គ្រឿងម៉ាក BEAT ពាក់ស្លាកលេខ ភ្នំពេញ 1IQ-4104 ។ ចាប់តាំងពេលដែលចាប់ដៃគ្នាជាប្តីប្រពន្ធមក



Scanned with CamScanner

ចេះតែមានរឿងរកាំរកុះនឹងគ្នា និងមានការឈ្លោះប្រកែកគ្នាជាញឹកញាប់ ដោយសារការមិនយល់ចិត្តគ្នា មូលហេតុទាំងនេះធ្វើឲ្យខ្លួន អស់មនោសញ្ចេតនា មិនអាចរួមរស់ជាប្តីប្រពន្ធតទៅទៀតបានឡើយ។

*៣-ការអះអាងរបស់ភាគី:*

-ដើមចោទឈ្មោះ [redacted] **រ៉ាយ៉ា** បានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខៈ០៨ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤។ នៅក្នុងការរួមរស់នៅជាមួយគ្នាមានៈ កូនឈ្មោះ [redacted] សុវណ្ណឧត្តម ភេទប្រុស កើតថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥។ ដីឡូតិ៍ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៤០៧០៨០៦.១៤៩៩ លេខក្បាលដី១៤៩៩ ទំហំ ២២៦ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែសារ ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង,ផ្ទះល្វែងស្ថិតនៅបុរី ប៊ីអូអេស (BOS)ក្បាលដីលេខ ២៣៦ ផ្ទះលេខ B14 ភូមិព្រៃសណ្តែក សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ,ម៉ូតូ០១គ្រឿងម៉ាក BEAT ពាក់ស្លាកលេខ ភ្នំពេញ 1IQ-4104 និងជំពាក់បំណុលម្តាយខ្លួនចំនួន ៥៥០០ $(ប្រាំពាន់ប្រាំរយដុល្លាអាមេរិក) ក្នុងការទិញបង់រំលោះផ្ទះ។ ក្រោយមកពួកខ្លួនចេះតែទាស់ខ្វែងគំនិតគ្នា និងមិនចុះសំរុងគ្នា ជាញឹកញាប់ រហូតដល់ខ្លួនអស់មនោសញ្ចេតនា ក្នុងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធតទៅទៀត ទើបខ្លួនសម្រេចចិត្តប្តឹងមកសាលាដំបូងដើម្បីសុះសាលក្រមដូចខាងលើ។

-ចុងចម្លើយឈ្មោះ [redacted] **លីវ៉ាន់នី** បានធ្វើសេចក្តីថ្លែងការតបថា ខ្លួនមិនព្រមលែងលះទេ ព្រោះខ្លួននៅតែស្រលាញ់ប្តី កូនក៏ខ្លួនមិនព្រមឲ្យទៅដើមចោទដែរ សព្វថ្ងៃកូនកំពុងរស់ជាមួយខ្លួន ដីនៅខេត្តព្រះវិហារខ្លួនបញ្ចាំគេតម្លៃ ៣ ០០០ ០០០រៀល(បីលាន)ឯបំណុលជំពាក់គេ ៦០០០$(ប្រាំមួយពាន់)ដុល្លារអាមេរិក ឯក្រៅពីនោះគឺខ្លួនឯកភាពតាមការលើកឡើងរបស់ដើមចោទ។

*៤-ចំណុចវិវាទ* ៖ ការសុំលែងលះ ,សិទ្ធិគ្រប់គ្រងកូន,ទ្រព្យសម្បត្តិរួម,បំណុល ។

*៥-ចំណុចគ្មានវិវាទ*៖ គ្មាន ។

## **សំអាងហេតុ**

១-តាមពាក្យបណ្តឹងចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ របស់ដើមចោទ បានបញ្ជាក់ថាខ្លួន និងចុងចម្លើយមានអាសយដ្ឋាននៅភូមិបឹងកណ្តាល ឃុំខ្ពបអាទាវ ស្រុកលើកដែក ខេត្តកណ្តាល គឺមានលក្ខណៈត្រឹមត្រូវតាមមាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីតុលាការលើកមកពិចារណានិងសម្រេចបាន។

២.ដើមចោទនិងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខៈ០៨ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ ត្រឹមត្រូវតាមច្បាប់ ហើយដើមចោទបានសុំលែងលះពីចុងឈ្មោះ [redacted] លីវ៉ាន់នី ដោយហេតុថា ក្នុងការរស់នៅជាមួយគ្នានោះ ពួកខ្លួនតែងតែមានគំនិតខ្វែងនិងទាស់គ្នាជាញឹកញាប់ និងបានរស់នៅបែកគ្នាអស់រយៈពេលជាង ០២ ឆ្នាំមកហើយ ទោះបីតុលាការខិតខំសាកល្បងធ្វើការផ្សះផ្សាក៏ដោយ ក៏ភាគីនៅតែសុំលែងលះដោយ ខ្លួនអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធតទៅអនាគតបាន ។ តុលាការយល់ឃើញថា មានមូលហេតុសមស្របត្រឹមត្រូវតាមច្បាប់ នឹងចំណងអាពាហ៍ពិពាហ៍លែងមានន័យទៀតហើយ គប្បីតុលាការសម្រេចតាមមាត្រា ៩៧៨ ,មាត្រា ៩៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។



Scanned with CamScanner

៣-ទ្រព្យសម្បត្តិរួមមាន៖ ដីឡូតិ៍ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៤០៧០៨០៦.១៤៩៩ លេខក្បាលដី១៤៩៩ ទំហំ២២៦ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែសារ ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង,ផ្ទះល្វែងស្ថិតនៅបូរី ប៊ីអូអេស (BOS)ក្បាលដីលេខ ២៣៦ ផ្ទះលេខ B14 ភូមិព្រៃសណ្តែក សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ,ម៉ូតូ០១គ្រឿងម៉ាក BEAT ពាក់ស្លាកលេខភ្នំពេញ 1IQ-4104 និងជំពាក់បំណុលម្តាយខ្លួនចំនួន ៥៥០០ $(ប្រាំពាន់ប្រាំរយដុល្លាអាមេរិក) ក្នុងការទិញបង់រំលោះផ្ទះ។ ឃើញថា គូភាគីមិនបានព្រមព្រៀងគ្នាចែក គប្បីតុលាការធ្វើការបែងចែកទៅតាមច្បាប់។

៤.ចំពោះប្រាក់ជាបំណុលជំពាក់គេដែលដើមចោទថាមានចំនួន ៤០០០ $(បួនពាន់ដុល្លាអាមេរិក) និងចុងចម្លើយថា មានចំនួន ៦០០០$(ប្រាំមួយពាន់ដុល្លាអាមេរិក) តុលាការមិនលើកមកពិចារណាឡើយ ព្រោះថា ពុំមានឯកសារច្បាស់លាស់និងភាគីម្ចាស់បំណុលពុំបានដាក់ពាក្យបណ្តឹងទាមទារឡើយ។

៥.ចំពោះកូនឈ្មោះ[redacted] សុវណ្ណឧត្តម កើតនៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥ ទើបតែមានអាយុ ៧ ឆ្នាំ ៤ ខែ២៤ថ្ងៃ គឺនៅតូច ហើយសព្វថ្ងៃស្ថិតនៅជាមួយចុងចម្លើយគ្រប់គ្រងថែរក្សា ចុងចម្លើយក៏សុំគ្រប់គ្រងកូនដែរ ចុងចម្លើយមានមុខរបរត្រឹមត្រូវ និងសមត្ថភាពក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន គប្បីតុលាការសម្រេចតាមការទាម ទារនេះដោយយោងតាមមាត្រា១០៣៧ និងមាត្រា ១០៣៨ នៃក្រមរដ្ឋប្បវេណី ។

៦.ចុងចម្លើយពុំបានទាមទារប្រាក់អាហារការតព្វកិច្ចដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូនទេ តុលាការមិនពិចារណាសម្រេចអំពីប្រាក់ហារកាតព្វកិច្ចទេ។

៧.ចំពោះប្រាក់ប្រដាប់ក្តី តុលាការគប្បីឲ្យភាគីដើមចោទជាអ្នកទទួលបន្ទុក តាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## <u>សេចក្តីសម្រេចបញ្ចប់</u>

**១**-ឲ្យដើមចោទឈ្មោះ[redacted]**៉ាយ៉ា** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរ មន្ត្រីនគរបាល ទីលំនៅបច្ចុប្បន្ននៅ[redacted] <u>**លែងលះ**</u> ពីចុងចម្លើយឈ្មោះ[redacted] **លីវ៉ាន់នី** ភេទស្រី អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ មេផ្ទះ ទីលំនៅបច្ចុប្បន្ននៅ[redacted]។

២-ប្រគល់អំណាចមេបាលើ៖ កូនឈ្មោះ[redacted] **សុវណ្ណឧត្តម** ភេទប្រុស កើតថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៥ ទៅឲ្យចុងចម្លើយឈ្មោះ[redacted]**លីវ៉ាន់នី** ជាអ្នកគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សានិងទុកសិទ្ធិឲ្យដើមចោទជាឪពុកដែលមិនបានទទួលសិទ្ធិអំណាចមេបា អាចទៅសាកសួរសុខទុក្ខប្រាស្រ័យទាក់ទងជាមួយកូនគ្រប់ពេលវេលាតាមការនឹករលឹក។

**៣-ទ្រព្យសម្បត្តិរួម៖**

៣.១.ផ្ទះល្វែងស្ថិតនៅបូរី ប៊ីអូអេស (BOS)ក្បាលដីលេខ ២៣៦ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១២០៩០២២៣.០២៣៦ ផ្ទះលេខB14 ភូមិព្រៃសណ្តែក សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

៣.២.ដីឡូតិ៍ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៤០៧០៨០៦.១៤៩៩ លេខក្បាលដី១៤៩៩ ទំហំ ២២៦ម៉ែត្រការ៉េ ស្ថិតនៅភូមិស្រែសារ ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ



Scanned with CamScanner

ខេត្តកំពង់ឆ្នាំង ម៉ូតូ០១គ្រឿងម៉ាក BEAT ពាក់ស្លាកលេខ ភ្នំពេញ 1IQ-4104 ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

ថ្ងៃអង្គារ១០រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ពស ២៥៦៧

ខេត្តកណ្តាល,ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃអង្គារ ១០រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ពស ២៥៦៧

ខេត្តកណ្តាល ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner